## សេវកម្មសុខភាពផ្លូវចិត្តឯកជន

បើអ្នកមានការធានារ៉ាប់រងសុខភាពឯកជន អ្នកអាចជាវសេវកម្មពីមន្ទីរព្យាបាលឯកជន, អ្នកព្យាបាលវិកលចរិត,មជ្ឈមណ្ឌលព្យាបាល សុខភាពផ្លូវចិត្តនៅសហគមន៍ ឬពីមន្ទីរថែអ្នកជំងឺសំរាកក្នុងមន្ទីរពេទ្យធ្ងន់ធ្ងរដោយផ្ទាល់ ។ បើអ្នកជាសមាជិកនៃអង្គការថែទាំសុខភាព(Health Maintenance Organization) ចូរទូរស័ព្ទទៅអ្នកតំណាងផ្នែកបំរើភ្ញៀវរបស់អ្នក ដើម្បីបានពត៌មានល្អិតល្អន់ អំពីការគ្រប់គ្រងសុខភាពផ្លូវចិត្តរបស់អ្នក ។ បើអ្នកជាគ្រួសារកងទ័ព,ចូរទាក់ទងអ្នកតំណាងនៃមន្ទីរថែទាំហៅថា Tri-Care/ Tri-West របស់អ្នកលេខ 1-800-404-4506 ឬ មើលតាមអ៊ិនធើណិត www.Triwest.com ។

# ត្តដោយវិធីណា?

បើការគ្រប់គ្រងរបស់អ្នក បានប្រើដល់កំរិតរបស់គេហើយ ឬបើអ្នកមិនមានការធានារ៉ាប់រងទេ អ្នកប្រហែលអាចជាវសេវកម្មនេះតាមកំរិតតំលៃកំណត់។ ចូរទាក់ទងបណ្តាញឧបត្ថម្ភបំរើក្នុងតំបន់អ្នក ដើម្បីរកទីភ្នាក់ងារដែលផ្តល់ជូនសេវកម្មតាមកំរិតតំលៃបន្តិចបន្តួច។បណ្តាញឧបត្ថម្ភប្រចាំតំបន់មានចុះនៅខាងខ្នងនៃកូនសៀវភៅនេះ ។ ម្យ៉ាងទៀត អ្នកអាចទាក់ទងទីភ្នាក់ងារថែសុខភាពសតិអារម្មណ៍ដោយផ្ទាល់តែម្តងក៏បាន ដើម្បីសាកសួរអំពីកំរិតតំលៃកំណត់ទាំងនេះ ។

## Washington Basic Health Plan (ផែនការមូលដ្ឋានសុខភាពរដ្ឋវ៉ាស៊ិនតោន)

The Washington Basic Health Plan មានជំនួយការព្យាបាលសុខភាពសតិអារម្មណ៍នេះខ្លះដែរ ។ ចូរឆែករកមើលក្នុងផែនការផ្នែកពេទ្យរបស់អ្នកសំរាប់ការគ្រប់គ្រងនេះ ។

| **Basic Health Plan** (ផែនការមូលដ្ឋានសុខភាព) | ទូរស័ព្ទ |
|---|---|
| Columbia United Providers | 800-315-7862 |
| Community Health Plan of Washington | 800-440-1561 |
| Group Health Cooperative | 888-901-4636 |
| Kaiser Foundation Health Plan | 800-813-2000 |
| Molina Healthcare of WA Inc. | 800-869-7165 |
| Molina Healthcare of WA Inc. | 800-691-3072 |
| Regence Blue Shield/ Asuris Northwest Health | 800-669-8791 (Regence)<br>866-240-9560 (Asuris) |

**គឺជាការសំខាន់ណាស់ដែលអ្នកឆែកមើលជាមួយអ្នកទទួលរ៉ាប់រង សំរាប់ការអនុញ្ញាតតាមការដែលបានតម្រូវ មុននឹងស្វែងរកប្រភេទនៃការថែទាំណាមួយសំរាប់កូនរបស់អ្នក ។**

## សេវកម្មផ្នែកវិបត្តិ

សេវកម្មផ្នែកវិបត្តិមានផ្តល់ជូនដល់ជនគ្រប់គ្នា តាមរយៈប្រព័ន្ធសាធារណៈ ដោយមិនយកថ្លៃឡើយ ។ ទោះជាអ្នកមានការធានារ៉ាប់រងសុខភាពឯកជនក៏ដោយ ភាពងាយស្រួលនៃការស្នាក់នៅក្នុងកម្មវិធីសំរាប់អ្នកជម្ងឺសំរាកក្នុងមន្ទីរពេទ្យរយៈពេលយូររបស់កូនអ្នកនឹងផ្តល់ជំនួយតាមរយៈប្រាក់សាធារណៈ។ ចូរមើលទំព័រម្ខាងសំរាប់ពត៌មានល្អិតល្អន់ ។

## បណ្តាញឧបត្ថម្ភតំបន់ (Reginal Support Network)

| Regional Support Network (RSN)* / county - ខោនធី / counties - ខោនធីច្រើន | លេខទូរស័ព្ទ | បណ្តាញទូរស័ព្ទផ្នែកវិបត្តិ |
|---|---|---|
| Chelan and Douglas Counties | 877-563-3678 | 800-852-2923 |
| Clark County | 800-410-1910 | 800-626-8137 |
| Grays Harbor County | 800-464-7277 | 800-685-6556 |
| Greater Columbia Counties | 800-795-9296 | 800-671-5437 |
| *Asotin* | | *888-475-5665* |
| *Benton-Franklin* | | *800-548-8761* |
| *Columbia* | | *866-382-1164* |
| *Garfield* | | *888-475-5665* |
| *Kittitas* | | *509-925-9861* |
| *Klickitat* | | *800-572-8122* |
| *Skamania* | | *509-427-3850* |
| *Toppenish* | | *800-500-1344* |
| *Walla Walla* | | *509-522-4278* |
| *Whitman* | | *866-871-6385* |
| *Yakima* | | *800-572-8122* |
| *Yakima Children* | | *800-671-5437* |
| King County | 800-790-8049 | 866-427-4747 |
| North Central Counties | 800-251-5350 | |
| *Adams (ទូរស័ព្ទឲ្យអ្នកទទួលចេញថ្លៃ)* | | *509-488-5611* |
| *Ferry* | 866-268-5105 | |
| *Grant* | | *877-467-4303* |
| *Lincoln* | | *800-767-6081* |
| *Okanogan* | | *866-826-6191* |
| *Pend Oreille* | | *866-847-8540* |
| *Stevens* | | *888-380-6823* |
| North Sound Counties *Island, Skagit, San Juan, Snohomish, Whatcom* | 888-693-7200 | 800-584-3578 |
| Peninsula Counties | 800-525-5637 | |
| *East Clallam County* | | *360-452-4500* |
| *West Clallam County* | | *360-374-5011* |
| *Kitsap* | | *800-843-4793* |
| *East Jefferson County* | | *800-659-0321* |
| *West Jefferson County* | | *360-374-5011* |
| Pierce County | 800-531-0508 | 800-576-7764 |
| Cowlitz County | 800-347-6092 | 800-803-8833 |
| Spokane County | 800-273-5864 | 877-678-4428 |
| Thurston and Mason Counties | 800-624-1234 (x5585) | 800-627-2211 |
| Timberlands Counties | 800-392-6298 | |
| *Lewis* | | *800-559-6696* |
| *Pacific* | | *800-884-2298* |
| *Wahkiakum* | | *800-635-5989* |

Mental Health Division ........ 800-446-0259
PO Box 45320 • Olympia, WA 98504-5320 • www1.dshs.wa.gov/mentalhealth/

* ពត៌មាននេះអាចប្រែប្រួល ហើយត្រូវធ្វើឲ្យមានបច្ចុប្បន្នភាពតាមរយៈអ៊ិនធើណិតនៃ MHD ជារៀងរាល់ខែ ។
www1.dshs.wa.gov/mentalhealth/rsnmap.shtml



# តើសេវកម្មសុខភាពសតិអារម្មណ៍ គឺសំរាប់ សេវាកម្មសុខភាព កុមារាកុមារី និង

Washington State Department of Social & Health Services
DSHS 22-644 CA (Rev. 9/06)

# តើខ្ញុំរកសេវកម្ម សុខភាពផ្លូវចិត្តដោយវិធីណា?



## 1 សេវកម្មសុខភាពសតិអារម្មណ៍សាធារណ: ។

បើអ្នកទទួលកម្មវិធីម៉េឌីខេដ អ្នកត្រូវបានគេចុះឈ្មោះដោយស្វ័យប្រវត្តិក្នុងផែនការថែសុខភាពសតិអារម្មណ៍មួយហៅថា *Reginal Support Network (RSN)*។ បើអ្នកមិនមានការធានារ៉ាប់រងសុខភាពទេ សេវកម្មថែសុខភាពសតិអារម្មណ៍ អាចមានផ្តល់ជូនទៅតាមកំរិតតំលៃកំណត់ ។ ចូរទូរស័ព្ទ RSN របស់អ្នក សំរាប់ដឹងពតិមានពីអ្នកដែលផ្តល់ការបំរើទៅតាមកំរិតតំលៃកំណត់ ។

បើអ្នកទទួលកម្មវិធីម៉េឌីខេដ អ្នកអាចទទួលការព្យាបាលសុខភាពសតិអារម្មណ៍ពីទីភ្នាក់ងារដែលមានការអនុញ្ញាតិពី RSN ប៉ុណ្ណោះ ។ សេវកម្មសំរាប់អ្នកជំងឺក្រៅ និងអ្នកដេកពេទ្យមានភាពធ្ងន់ធ្ងរ ត្រូវមានការអនុញ្ញាតពី RSN ប្រចាំតំបន់អ្នក ។ បើអ្នកទទួលសេវកម្មពីគ្រូពេទ្យ ដែលមិនមានការអនុញ្ញាតិពី RSN អ្នកប្រហែលជាត្រូវទទួលរ៉ាប់រងចេញប្រាក់ការ ព្យាបាល។

### សេវកម្មផ្នែកវិបត្តិ

បើសិនជាភាពអាសន្នគំរាមដល់ជីវិត ចូរទូរស័ព្ទ 911 ។ បើកូនអ្នកស្ថិតនៅក្នុងផ្នែកវិបត្តិសុខភាពសតិអារម្មណ៍ ចូរទូរស័ព្ទតាមបណ្តាញផ្នែកវិបត្តិដែលមានក្នុងខោនធីរបស់អ្នក ដែលមានចុះនៅខាងខ្នងនៃកូនសៀវភៅនេះ ។ ជំនួយគឺអាចមានក្នុងរយ:ពេលម្ភៃបួនម៉ោងរៀងរាល់ថ្ងៃ ។ បុគ្គលិកប្រចាំបណ្តាញទូរស័ព្ទផ្នែកវិបត្តិ នឹងធ្វើការប៉ាន់ប្រមាណនូវស្ថានភាពនេះ ហើយប្រសិនបើចាំបាច់ គេនឹងប៉ាន់ប្រមាណមើលជំងឺរបស់កូនអ្នក ។

### សេវកម្មអ្នកជំងឺក្រៅ

កន្លែងដែលអ្នកនៅ នឹងកំណត់ថាតើទីភ្នាក់ងារណាមួយ ដែលនឹងអាចផ្តល់សេវកម្មដល់កូនអ្នក ។ ចូរទូរស័ព្ទ RSN តំបន់អ្នក ដើម្បីស្នើរកពតិមានសំរាប់ការទាក់ទង ទីភ្នាក់ងារថែសុខភាពសតិអារម្មណ៍ដែលបំរើក្នុងតំបន់អ្នក ។ ចូរទាក់ទង ទីភ្នាក់ងារនោះ ដើម្បីណាត់ពេលជួប ។ បុគ្គលិកប្រចាំទីភ្នាក់ងារ នឹងប៉ាន់ប្រមាណកូនអ្នក ដើម្បីកំណត់ថាតើកូនអ្នកមានជំងឺសតិអារម្មណ៍ឬយ៉ាងណា ហើយជួបតាមលក្ខណសម្បត្តិនៃការតម្រូវសំរាប់សេវកម្មនេះឬទេ ។

### សេវកម្មអ្នកជំងឺធ្ងន់ធ្ងរដែលសំរាកក្នុងមន្ទីរពេទ្យ

សេវកម្មអ្នកជំងឺធ្ងន់ធ្ងរដែលសំរាកក្នុងមន្ទីរពេទ្យ ត្រូវគេផ្តល់ជូនទៅតាមស្ថានភាពបន្ទាន់អាសន្ន នៅពេលកូនអ្នកត្រូវពិការយ៉ាងធ្ងន់ធ្ងរឬហាក់ដូចជាធ្វើឲ្យមានគ្រោះថ្នាក់ដល់ខ្លួនឯង ឬដល់អ្នកដទៃ ដោយសារលទ្ធផលនៃជម្ងឺសតិអារម្មណ៍នេះ ។ អ្នកមានវិជ្ជាជីវ:ផ្នែកសុខភាពសតិអារម្មណ៍(MHP) នឹងធ្វើការប៉ាន់ប្រមាណនូវលក្ខណ:របស់កូនអ្នក ហើយធ្វើការកំណត់នោះ ។ ដើម្បីបានទទួលសេវកម្មនេះ ចូរទូរស័ព្ទបណ្តាញផ្នែកវិបត្តិ RSN ។ បើសិនជាស្ថានភាពនោះ ជាការគំរាមដល់ជីវិត ចូរទូរស័ព្ទ 911 ។

### សេវកម្មអ្នកជំងឺសំរាកក្នុងមន្ទីរពេទ្យរយ:ពេលយូរ

ការថែទាំអ្នកជំងឺសំរាកក្នុងមន្ទីរពេទ្យរយ:ពេលយូរ គឺជាការដាក់ខាងផ្នែកវិកលវិត ដោយភាពតឹងរ៉ឹងជាទីបំផុតសំរាប់ក្មេងនៅក្នុងរដ្ឋនេះ ។ គឺសំរាប់ក្មេងដែលមានសេចក្តីត្រូវការផ្នែកសុខភាពសតិអារម្មណ៍យ៉ាងធ្ងន់ធ្ងរនិងយ៉ាងល្អិតល្អន់បំផុត ។ ក្មេងដែលមានលក្ខណសម្បត្តិសំរាប់ការថែទាំជាអ្នកជំងឺសំរាកក្នុងមន្ទីរពេទ្យរយ:ពេលយូរ ត្រូវសំរាកក្នុងមន្ទីរពេទ្យដោយគ្មានជំរើសពីកន្លែងទាំងអស់ ហើយនិងត្រូវជួបតាមគោលការណ៍ណែនាំរបស់សហព័ន្ធនិងរដ្ឋសំរាប់ទទួលការបំរើនានា ។ RSN នឹងធ្វើការជាមួយអ្នក និងប្រព័ន្ធឧបត្ថម្ភរបស់អ្នក ដើម្បីសំរេចមើលថាតើ ការថែទាំជាអ្នកជំងឺសំរាកក្នុងមន្ទីរពេទ្យរយ:ពេលយូរត្រូវបានអនុញ្ញាតឬទេ ។ ចូរទាក់ទង RSN របស់អ្នកដើម្បីពតិមានច្រើនទៀត ។

## 2 សេវកម្មសាធារណ:សំរាប់អ្នកក្រៅ

បើកូនអ្នកនៅក្រោមអាយុដប់បីឆ្នាំ ត្រូវមានការយល់ព្រមពីអ្នកសំរាប់ការព្យាបាល ។ បើកូនអ្នកអាយុចាប់ពីដប់បីឆ្នាំឡើង ទៅ កូនអ្នកអាចស្នើសុំនិងទទួលការព្យាបាលដោយមិនចាំមានការព្រមព្រៀងពីអ្នក ។

សេវកម្មថែសុខភាពសតិអារម្មណ៍មួយចំនួនធំ មានផ្តល់នៅក្នុងសហគមន៍ តាមគោលការណ៍នៃអ្នកជំងឺក្រៅ ។ បង្កើនពីលើនេះទៀត ការព្យាបាលសុខភាពសតិអារម្មណ៍អ្នកជំងឺក្រៅសំរាប់ក្មេង ហើយនិងយុវជន គឺត្រូវចេញឲ្យឆ្ងាយពីការទៅជួបពេទ្យនៅការិយាល័យពីមុន ។

- គេអាចផ្តល់សេវកម្មទាំងនេះ តាមការតម្រូវជាធម្មតា ដូចជានៅផ្ទះ,សាលារៀន ឬពេលកំពុងចូលរួមនិងសកម្មភាពពេលម៉ោង កំសាន្ត ។
- ឪពុកម្តាយហើយបើសិនជាសមរម្យ ក្មេង ហើយនិងអ្នកព្យាបាលអាចបង្កើតផែនការព្យាបាលជាមួយគ្នា ។ ផែនការព្យាបាលគួរជួបតាមសេចក្តីត្រូវការមួយៗរបស់ក្មេង ហើយនិងគ្រួសារអ្នក ។
- ផែនការបំរើគួររួមទាំងសេវាកម្មចម្រុះជាផ្លូវការនឹងក្រៅផ្លូវការ ដើម្បីឲ្យកូនអ្នកអាចរស់នៅបាន តាមរបៀបការរស់នៅ ដូចជាក្មេងដទៃទៀតដែរ ។
- ឪពុកម្តាយត្រូវរកវិធីធ្វើឲ្យមានប្រសិទ្ធិភាព ដើម្បីចូលរួមក្នុងក្រុមឧបត្ថម្ភ ដែលជួយសម្រួលដោយឪពុកម្តាយដទៃទៀត។

**ការព្យាបាលក៏អាចរួមបញ្ចូលទាំង:**

- ការនិយាយជាមួយនិងអ្នកព្យាបាល
- ការទិញ និងត្រួតពិនិត្យថ្នាំ
- ការប្រជុំឱវាទណែនាំជាក្រុម និងជាគ្រួសារ
- ការអប់រំលើភាពមិនប្រក្រតី,ធនធាន,និងកម្មវត្ថុផ្សេងៗដែលគ្រួសារចូលចិត្ត
- ក្រុមឧបត្ថម្ភ និងគាំទ្រគ្រួសារ
- ការរៀបចំសំណុំរឿង ដើម្បីជួយចាត់ចែងសេវកម្មទាំងនេះ
- ការបញ្ជូនទៅអង្គការនៅក្នុងសហគមន៍របស់អ្នក ។
- មានក្រុមសំរាប់ឧបត្ថម្ភក្មេង ហើយនិងគ្រួសាររបស់អ្នក ។

## 3 សេវកម្មសាធារណ:សំរាប់អ្នកជំងឺធ្ងន់ធ្ងរសំរាកក្នុងមន្ទីរពេទ្យ

បើ MHP សំរេចថា កូនអ្នកត្រូវសំរាកក្នុងពេទ្យ, MHP នឹងជួយរកមន្ទីរពេទ្យឲ្យសមនិងសេចក្តីត្រូវការ ។ បើកូនអ្នកក្រោមអាយុដប់បីឆ្នាំ គេមិនអាចឲ្យកូនអ្នកសំរាកក្នុងមន្ទីរពេទ្យ ដោយមិនមានការអនុញ្ញាតិពីអ្នកបានឡើយ ។ បើកូនអ្នកអាយុចាប់ពីដប់បីឆ្នាំឡើងទៅ ការព្រមព្រៀងរបស់គេគឺអាចតំរូវឲ្យមាន ។

### អ្នកអាចយកកូនមិនទាន់គ្រប់អាយុ ទៅកាន់មន្ទីរប៉ាន់ប្រមាណ និងមន្ទីរព្យាបាល

ឬទៅកាន់មន្ទីរអ្នកជំងឺសំរាកក្នុងមន្ទីរពេទ្យណាមួយទៀត ដែលផ្តល់សេវកម្មថែសុខភាពសតិអារម្មណ៍ ហើយស្នើឲ្យគេប៉ាន់ប្រមាណ ដើម្បីកំណត់ថាតើកូនអ្នកមានសតិអារម្មណ៍វិបល្លាស ហើយត្រូវការការព្យាបាលសុខភាពសតិអារម្មណ៍ជាអ្នកជំងឺសំរាកក្នុងមន្ទីរពេទ្យ ។ បើអ្នកនាំមិនទាន់គ្រប់អាយុទៅកាន់មន្ទីរនោះ ការព្រមព្រៀងរបស់កូនមិនទាន់គ្រប់អាយុរបស់អ្នកមិនតំរូវឲ្យមានសំរាប់ការវាយតំលៃទេ ។ គេមិនតម្រូវឲ្យមន្ទីរនោះផ្តល់ការព្យាបាលសុខភាពសតិអារម្មណ៍ដល់កូនអ្នកទេ ប៉ុន្តែពួកគេក៏មិនអាចបដិសេធការព្យាបាលកូនអ្នកតែឯងដែរ ពីព្រោះកូនអ្នកមិនបានព្រមព្រៀងដើម្បីព្យាបាលសុខភាពសតិអារម្មណ៍នេះឡើយ ។

ការប៉ាន់ប្រមាណកំណត់ថាកូនអ្នកមានសុខភាពសតិអារម្មណ៍វិបល្លាសឬយ៉ាងណានោះ នឹងត្រូវបំពេញក្នុងរវាង២៤ម៉ោងដោយអ្នកមានវិជ្ជាជីវ:ខាងផ្នែកសុខភាពសតិអារម្មណ៍ ។ អ្នកមានវិជ្ជាជីវ: អាចកំណត់ថា គេត្រូវការពេលបន្ថែមចាំបាច់ដើម្បីធ្វើឲ្យមានស្ថេរភាពអាការ:រោគរបស់កូនអ្នក ធ្វើដូច្នេះដើម្បីបំពេញការប៉ាន់ប្រមាណ ។ គឺគ្មានព្រឹត្តិការណ៍នឹងប្រើពេល សំរាប់ការប៉ាន់ប្រមាណកូនអ្នក លើសពី៧២ម៉ោងឡើយ ។

### ការសំរាកក្នុងមន្ទីរពេទ្យដោយស្ម័គ្រចិត្ត:

បើកូនអ្នកអាយុចាប់ពីដប់បីឆ្នាំឡើងទៅ កូនអ្នកអាចរកការអនុញ្ញាតិដោយស្ម័គ្រចិត្ត ដើម្បីចូលទៅកាន់មន្ទីរពេទ្យ ដើម្បីព្យាបាលឬផ្លាស់ប្តូរការអនុញ្ញាតិដោយមិនស្ម័គ្រចិត្ត ឲ្យទៅជាការអនុញ្ញាតិដោយស្ម័គ្រចិត្តវិញ ដោយមិនចាំមានសេចក្តីអនុញ្ញាតិពីអ្នកឡើយ។ ថ្វីបើអ្នក មិនយល់ស្របតាមសេចក្តីសំរេចរបស់កូនអ្នក ដើម្បីរកការព្យាបាលនេះក៏ដោយ គឺវាជាអត្ថប្រយោជន៍របស់កូនអ្នក បើអ្នកគាំទ្រកូនអ្នកតាមរយ:ពេលដ៏លំបាកនេះ ។

### ការសំរាកក្នុងមន្ទីរពេទ្យដោយមិនស្ម័គ្រចិត្ត:

បើគេបានកំណត់ថា កូនអ្នកត្រូវមានការព្យាបាល ហើយមិនចង់ឲ្យគេអនុញ្ញាត អ្នកមានវិជ្ជាជីវ:ខាងផ្នែកសុខភាពសតិអារម្មណ៍ អាចអនុញ្ញាតឲ្យទុកកូនអ្នកបានដល់ចិតសិបពីរម៉ោង ដើម្បីប៉ាន់ប្រមាណ និងធ្វើឲ្យមានស្ថេរភាព ។ បើមន្ទីរសំរេចថា ត្រូវតែបន្តការព្យាបាលទៀត ជាការចាំបាច់ កូនអ្នកអាចស្ម័គ្រចិត្តយល់ព្រមដើម្បីការព្យាបាលតទៅមុខទៀតបាន ឬមន្ទីរអាចរកមន្ទីរពេទ្យសំរាប់ការមិនស្ម័គ្រចិត្តនេះឲ្យ ។ មន្ទីរពេទ្យអាចស្នើសុំសវនាការតុលាការ សំរាប់ការដេកពេទ្យបន្ថែមពីលើនេះបានរយ:ដប់បួនថ្ងៃទៀត ។ បន្ទាប់ពីរយ:ដប់បួនថ្ងៃនេះបានចប់មក មន្ទីរពេទ្យអាចធ្វើទិដ្ឋាការជាមួយតុលាការ ដើម្បីឲ្យនៅដេកពេទ្យបានដល់ទៅ១៨០ថ្ងៃ ។

### មន្ទីរពេទ្យសំរាប់វិកលចរិតធ្ងន់ធ្ងរ

Children’s Hospital Regional Medical Center
4800 Sand Point Way NE
Seattle, WA 98105
206-987-2760 • លេខឥតថៃ 866-987-2000

Lourdes Counseling Center
1175 Carondelet Dr.
Richland, WA 99352
509-943-9104

Fairfax Hospital
10200 NE 132nd St.
Kirkland, WA 98034
425-821-2000 • លេខឥតថៃ 800-435-7221

Sacred Heart Medical Center
101 West Eighth Ave.
Spokane, WA 99220
509-474-4818

## 4 សេវកម្មអ្នកជំងឺសំរាកក្នុងមន្ទីរពេទ្យសាធារណ:រយ:ពេលយូរ

ការព្យាបាលអ្នកជំងឺសំរាកក្នុងមន្ទីរពេទ្យរយ:ពេលយូរ មិនមែនជាដំណោះស្រាយនោះទេ ប៉ុន្តែវាជាផ្លូវចាប់ផ្តើមរបស់កូនអ្នកឲ្យជាឡើងវិញ ។ ការឧបត្ថម្ភ និងការចូលរួមរបស់អ្នក នៅក្នុងការព្យាបាលនេះ នឹងជួយសម្រួលកូនអ្នកឲ្យបានជាឡើងវិញ ហើយត្រឡប់ទៅផ្ទះ ។

សេវកម្មអ្នកជំងឺសំរាកក្នុងមន្ទីរពេទ្យរយ:ពេលយូរ បានត្រូវផ្តល់ឲ្យដល់អ្នកស្រុកមានបួនមន្ទីរ ដែលត្រូវគេស្គាល់ថា Children's Long-Term Inpationt Programs (CLIP) ។ CLIP ដែលគេបានផ្តល់ឲ្យនេះ អាចទទួលព្យាបាលក្មេងបានដល់កៅសិបមួយនាក់និងយុវជនបានតែម្តងសំរាប់ម្នាក់, តាមធម្មតាតែងមានការរង់ចាំសិនមុននិងអាចឲ្យចូលបាន ។ ប្រភេទនៃសេវកម្មដែលបានផ្តល់នេះ មានរួមចូលការប៉ាន់ប្រមាណ,ថ្នាំ,សេវកម្មការងប់និងគ្រឿងញៀន,ការព្យាបាល,ការចាត់ចែងសំណុំរឿង,ការឧបត្ថម្ភ និងគាំទ្រពីឪពុកឬម្តាយ។

### កំណត់សំគាល់ដល់ឪពុកម្តាយ

ការចិញ្ចឹមកូនមានបញ្ហាផ្លូវចិត្ត,អាកប្បកិរិយា ឬមានសុខភាពសតិអារម្មណ៍វិបល្លាស ជាការមុខងារដ៏លំបាកបំផុត ដែលអ្នកនឹងមិនធ្លាប់មាន ។ ចូរកុំសាកល្បងធ្វើកិច្ចការនេះតែម្នាក់ឯង ។ ចូររកមើលឪពុកម្តាយដទៃទៀតដែលធ្លាប់មានបញ្ហាទាំងនេះ ហើយយល់អំពីភាពលំបាក ដែលអ្នកកំពុងប្រឈមមុខ ។ ពួកគេអាចផ្តល់ពតិមាន,គំនិត,ការឧបត្ថម្ភផ្លូវចិត្ត,ធនធាននានា និងជំនួយដល់អ្នក ជាមួយនឹងសេចក្តីរបស់អ្នកតាមរយ:ប្រព័ន្ធនានា ។ ចូរទូរស័ព្ទ SAFE WA លេខ 1-866-300-1998 ឬនាយកដ្ឋានសុខភាពផ្លូវចិត្ត 1-800-446-0258 ext 3 ។